

សេចក្តីសង្ខេបគោលនយោបាយស្តីពី

លទ្ធភាពបង់ភាគទានទៅក្នុងរបបសន្តិសុខសង្គម របស់កសិករខ្នាតតូចនៅកម្ពុជា

Funded by
the European Union

១. បញ្ហានៃការសិក្សាស្រាវជ្រាវ

កសិកម្មគឺជាឆ្អឹងខ្នងដ៏សំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា ដែលបានរួមចំណែកប្រមាណ២២.៨ភាគរយនៃផលិតផលក្នុងស្រុក សរុបក្នុងឆ្នាំ២០២១ និងបានផ្តល់ការងារប្រមាណ៣៨.៩ ភាគរយនៃការងារសរុប[1]។ វិស័យនេះបានដើរតួនាទីសំខាន់ណាស់ក្នុងការធានាសន្តិសុខស្បៀង និងស្ថិរភាពសង្គម។ ដោយមើលឃើញពីសារៈសំខាន់វិស័យនេះចំពោះសេដ្ឋកិច្ចជាតិ ការចូលរួមកាត់បន្ថយភាពក្រីក្រ និងជាប្រភពប្រាក់ចំណូលពីការនាំចេញ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រកសិកម្ម ដោយផ្តោតសំខាន់លើការជម្រុញផលិតភាព និងការប្រគួតប្រជែង[2]។ ទោះបីជាយ៉ាងនេះក្តី វិស័យនេះនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនធំ ដែលធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាពរបស់កសិករខ្នាតតូច ក៏ដូចជាបង្កហានិភ័យគួរឱ្យកត់សំគាល់ដល់ជីវភាពរស់នៅ និងវិបុលភាពសេដ្ឋកិច្ចជាតិ។ ភាពងាយរងគ្រោះដែលកសិករជួបប្រទះជាងគេ ក៏ដូចជាបញ្ហាប្រឈមធំៗបន្ទាន់ដែលត្រូវដោះស្រាយរួមមាន ការប្រឈមនឹងការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះផ្នែកបរិស្ថានភាពងាយរងគ្រោះផ្នែករូបវ័ន្ត និងសង្គម និងអស្ថិរភាពផ្នែកសេដ្ឋកិច្ច។



បម្រែបម្រួលអាកាសធាតុ បង្កជាការគំរាមកំហែងដ៏ធំធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី១២ ជាប្រទេសដែលមានភាពងាយរងគ្រោះ នៅទូទាំងពិភពលោក[3]។ កសិករខ្នាតតូចដែលពឹងផ្អែកខ្លាំងលើវិស័យកសិកម្មបានទទួលរងពីឥទ្ធិពលអាកាសធាតុទាំងក្នុងទម្រង់ធ្ងន់ធ្ងរ និងមិនសូវធ្ងន់ធ្ងរ បង្កឱ្យខូចខាតដល់ការដាំដុះ និងទិន្នផលកសិកម្ម បណ្តាលឱ្យបាត់បង់ប្រាក់ចំណូល និងកង្វះស្បៀងអាហារ បង្ខំឱ្យកសិករជំពាក់បំណុល និងប៉ះពាល់ដល់សន្តិសុខស្បៀង។



ស្ថានភាពខាងលើ បានបង្កើននូវបញ្ហាប្រឈមចំនួនពីរដល់កសិករខ្នាតតូចនៅកម្ពុជាគឺ **ហានិភ័យសុខភាព និងគ្រោះថ្នាក់ដែលទាក់ទងនឹងការងារ។** ការធ្វើកសិកម្មដែលពឹងផ្អែកខ្ពស់ទៅលើការប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វល្អិតបានបង្កហានិភ័យដល់សុខភាពសម្រាប់កសិករ។ បន្ថែមពីលើនេះ ការគ្រប់គ្រង និងទុកដាក់កាកសំណល់គីមីមិនបានល្អ បានបង្កឱ្យមានបញ្ហាសុខភាពកាន់តែធ្ងន់ធ្ងរឡើង។ កសិករប្រឈមមុខនឹងហានិភ័យទាំងនោះ តាមរយៈការការពារមិនបានល្អត្រឹមត្រូវ នាំឱ្យបង្កផលវិបាកធ្ងន់ធ្ងរដល់សុខភាព ដែលមិនត្រឹមតែប៉ះពាល់ដល់កសិករខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់គ្រួសារ និងអ្នកប្រើប្រាស់ផងដែរ[4]។

[1] ធនាគារពិភពលោក ២០២៣
[2] រាជរដ្ឋាភិបាល ២០២២
[3] Eckstein et al., (2019)
[4] Sim et al. (2021)

ហានិភ័យទាក់ទងនឹងវ័យចំណាស់ បានបង្កើនភាពងាយរងគ្រោះដល់កសិករខ្នាតតូចមួយកម្រិតថែមទៀត។ ដោយសារតម្រូវការការងារចាំបាច់សម្រាប់ក្នុងវិស័យកសិកម្ម កសិករវ័យចំណាស់ជាច្រើននៅតែបន្តចូលរួមធ្វើការងារនេះ បើទោះបីជាមានហានិភ័យជាច្រើនលើសពីសមត្ថភាពគ្រប់គ្រងរបស់ពួកគាត់ក៏ដោយ។ ការផ្លាស់ប្តូរប្រជាសាស្ត្រដែលមិនអាចចៀសផុតបាន ជាមួយនឹងការកើនឡើងនៃចំនួនប្រជាជនវ័យចំណាស់[5] តម្រូវឱ្យមានការយកចិត្តទុកដាក់ដោះស្រាយដល់បញ្ហាសុខភាព និងមុខរបរ ដែលកសិកវ័យចំណាស់កំពុងជួបប្រទះ។



អសន្តិសុខប្រាក់ចំណូល និងអស្ថិរភាពសេដ្ឋកិច្ច នៅតែបន្តជាបញ្ហាប្រឈម។ បើទោះបីអត្រាក្រីក្រនៅតាមជនបទបានធ្លាក់ចុះមួយកម្រិត ប៉ុន្តែភាពក្រីក្រនៅតែបន្តប្រទាញឡើងចុះពីកត្តាជាច្រើនដូចជា ការប្រែប្រួលតម្លៃទីផ្សារ ទិន្នផលកសិកម្មទាប និងផលប៉ះពាល់ពីខាងក្រៅ ដូចជាជំងឺរាតត្បាតកូវីដ-១៩ ជាដើម។ កម្រិតនៃការទទួលបានសេវាឥណទាន និងហិរញ្ញវត្ថុ និងកង្វះការធានារ៉ាប់រងផ្នែកដំណាំ បានរារាំងដល់លទ្ធភាពក្នុងការវិនិយោគលើមុខរបរ ដែលជាចំណែកបង្កើននូវកម្រិតអសន្តិសុខប្រាក់ចំណូលរបស់កសិករ។ លើសពីនេះទៅទៀត ទោះបីជាពួកគាត់មានតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម ប៉ុន្តែកសិករខ្នាតតូចនៅមិនទាន់ទទួលបានការដាក់បញ្ចូល និងទទួលបានរបបគាំពារសង្គមពេញលេញនៅឡើយ។ ទាំងនេះអាចបណ្តាលមកពីផ្នែកគោលនយោបាយនិងច្បាប់មិនទាន់គ្របដណ្តប់គ្រប់ជ្រុងជ្រោយ ផ្នែកហិរញ្ញវត្ថុ និងការទទួលបានព័ត៌មានជាដើម។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានការពង្រីកវិសាលភាពគាំពារសង្គមជាបន្ទាន់ដល់កសិករខ្នាតតូច។

២. ទិដ្ឋភាពទូទៅនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះបានផ្តួចផ្តើមឡើងដោយអង្គការអុកស្វាមកម្ពុជា ដើម្បីពិនិត្យមើលពីតម្រូវការគាំពារសង្គម និងលទ្ធភាពបង់ភាគទានរបស់កសិករខ្នាតតូចនៅកម្ពុជាទៅក្នុងរបបសន្តិសុខសង្គមដែលមានស្រាប់។ ការស្រាវជ្រាវនេះបានធ្វើឡើងចាប់ពីខែធ្នូ ឆ្នាំ២០២២ ដល់ ខែមីនា ឆ្នាំ២០២៣ ដោយធ្វើការវិភាគសំណាកកសិករខ្នាតតូចសរុបចំនួន៣៨៤នាក់ នៅក្នុងខេត្តចំនួន៥ (កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត និងព្រៃវែង ដែលគ្របដណ្តប់លើ ៤៥ឃុំ)។ ការសិក្សាបានផ្តោតលើ ការវាយតម្លៃពី ហានិភ័យ និងភាពងាយរងគ្រោះដែលកសិករខ្នាតតូចបានជួបប្រទះ ការយល់ដឹងរបស់ពួកគេអំពី ប.ស.ស. ការកំណត់ពីតម្រូវការ និងអាទិភាពគាំពារសង្គមដែលកសិករចង់បាន និងការវាយតម្លៃពីលទ្ធភាពផ្នែកហិរញ្ញវត្ថុរបស់កសិករខ្នាតតូចក្នុងការបង់ភាគទានទៅក្នុងរបបសន្តិសុខសង្គម។



[5] (NIS, 2019).

៣. របកគំហើញសំខាន់ៗ

ការវាយតម្លៃដោយខ្លួនឯង (ដោយកសិករដែលបានចូលរួមក្នុងការស្រាវជ្រាវ) អំពីហានិភ័យ និងភាពងាយរងគ្រោះ: *ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះនៃបរិស្ថាន* ទទួលបានពិន្ទុមធ្យមសរុប ៤.៦ (ក្នុងលំដាប់ពី ១ ដល់ ១០) លើព្រឹត្តិការណ៍អាកាសធាតុកម្រិតធ្ងន់ (ព្យុះស៊ីក្លូន) គ្រោះមហន្តរាយធម្មជាតិ ទឹកជំនន់ គ្រោះរាំងស្ងួត អគ្គីភ័យ ការប្រែប្រួលរដូវកាល សត្វដែលចម្លងមេរោគ និងការផ្ទុះជំងឺ។ សត្វដែលចម្លងមេរោគ និងការផ្ទុះជំងឺ ត្រូវបានអះអាងថាជាបញ្ហាគួរឱ្យព្រួយបារម្ភណ៍ជាទីបំផុត ដោយទទួលបានពិន្ទុមធ្យមខ្ពស់បំផុត៦.២។ រីឯគ្រោះរាំងស្ងួត ការប្រែប្រួលរដូវកាល និងព្រឹត្តការណ៍អាកាសធាតុកម្រិតធ្ងន់ ជាបញ្ហាគួរឱ្យព្រួយបារម្ភណ៍បន្ទាប់ពីសត្វដែលចម្លងមេរោគ និងការផ្ទុះជំងឺ។ *ភាពងាយរងគ្រោះផ្នែកវប្បធម៌* រួមមានលទ្ធភាពទទួលបានទឹក ថាមពលអគ្គិសនី មធ្យោបាយទំនាក់ទំនង និងការដឹកជញ្ជូន ទទួលបានពិន្ទុមធ្យមសរុប ៣.៩ ក្នុងនោះលទ្ធភាពប្រើប្រាស់ធនធានទឹកគឺជាការព្រួយបារម្ភខ្លាំងបំផុត។ *ភាពងាយរងគ្រោះផ្នែកសង្គម* គ្របដណ្តប់លើកត្តាជំងឺ មាតុភាព ការថែទាំកុមារ និងលក្ខខណ្ឌការងារដែលមានគ្រោះថ្នាក់ ទទួលបានពិន្ទុជាមធ្យម ៣.៨ ។ អ្នកថែទាំដែលមានសមាជិកគ្រួសារជាជនមានពិការភាពប្រឈមនឹងភាពងាយរងគ្រោះខ្ពស់ជាងគេបំផុត។ *ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច* រួមមានលទ្ធភាពទទួលបានប្រាក់កម្ចី ការប្រែប្រួលឡើងចុះនៃតម្លៃទីផ្សារ ទិន្នផលដំណាំទាប ទទួលបានពិន្ទុមធ្យម ៥.០។ ការប្រែប្រួលឡើងចុះនៃតម្លៃទីផ្សារក្លាយជាកត្តាសេដ្ឋកិច្ចដ៏ធំជាងគេ ដែលមានពិន្ទុមធ្យម ៦.២។ របកគំហើញទាំងនេះបញ្ជាក់ពីអន្តរកម្មដ៏ស្មុគស្មាញនៃហានិភ័យដែលកសិករខ្នាតតូចបាននិងកំពុងជួបប្រទះ ដែលត្រូវការកិច្ចអន្តរាគមន៍ផ្នែកគោលនយោបាយឱ្យចំគោលដៅ ដើម្បីពង្រឹងភាពធន់ចំពោះមុខនៃភាពមិនប្រាកដប្រជានៃការប្រែប្រួលបរិស្ថាន និងសេដ្ឋកិច្ច។

យន្តការដោះស្រាយ និងផែនការសម្រាប់អនាគត: ផ្អែកលើហានិភ័យដែលអាចកើតមាន ដូចជាហានិភ័យការងារ ហានិភ័យនៃវដ្តជីវិត ហានិភ័យធម្មជាតិ និងបរិស្ថាន អ្នកឆ្លើយតបបានកំណត់យន្តការដោះស្រាយមួយចំនួន និងផែនការនានា ដើម្បីធានាដល់សុវត្ថិភាពរបស់ពួកគេនៅពេលអនាគត ក្នុងនោះរួមមាន:



ការបាត់បង់ប្រាក់ចំណូល: ការសិក្សាបង្ហាញថា ៤៦.៤% នៃកសិករខ្នាតតូចបានយកប្រាក់សន្សំរបស់ពួកគេមកប្រើប្រាស់ ដើម្បីដោះស្រាយនៅពេលជួបស្ថានភាព ឬបញ្ហាអាក្រក់នានា។ លើសពីនេះទៀត ៤១.២% ពិចារណាលើការខ្ចីបុលពីអ្នកដទៃ។ ប្រសិនបើពិនិត្យលើភាពខុសគ្នានៃយេនឌ័រ កសិករជាស្ត្រីចំនួន ៤៤.៦% ចាប់អារម្មណ៍ក្នុងការខ្ចីបុលដើម្បីដោះស្រាយបញ្ហាជំងឺរយៈពេលវែង គ្រោះថ្នាក់ ឬពិការភាព រួមទាំងផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះធម្មជាតិ។



ការធ្វើផែនការសម្រាប់ពេលចូលវ័យចំណាស់ ៖ ទោះបីជាមានការព្រួយបារម្ភអំពីជីវភាពរបស់ពួកគាត់ក្នុងវ័យចាស់ក៏ដោយ កសិករខ្នាតតូចចាប់អារម្មណ៍ជាមួយនឹងបែបផែននៃការដោះស្រាយខុសគ្នា។ ជាង ៦១.៥% ទាំងបុរស (៦៣.៣%) និងស្ត្រី (៦០.៧%) ពឹងផ្អែកទៅលើការយកប្រាក់សន្សំរបស់ពួកគាត់មកប្រើប្រាស់ ខណៈដែល ៣៧.៨% ពឹងផ្អែកទៅលើការជួយពីគ្រួសារ ជាពិសេសពីកូនចៅរបស់ពួកគេ។



មាតុភាព និងការថែទាំសុខភាព: កសិករខ្នាតតូចជាស្ត្រី ដែលប្រឈមនឹងការចំណាយទ្វេដងទៅលើការសម្រាលកូន និងការថែទាំសុខភាព ពឹងផ្អែកទៅលើការប្រើប្រាស់ប្រាក់សន្សំរបស់ពួកគេ (៥៣.៦%) និងប្រាក់ចំណូលរបស់ប្តី ឬប្រពន្ធ ឬគ្រួសាររបស់ពួកគេ (៤១.៦%) ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុទាំងនោះ។



ការគ្រប់គ្រងការចំណាយក្នុងគ្រួសារ: ដើម្បីគ្រប់គ្រងការចំណាយក្នុងគ្រួសារលើសពីប្រាក់ចំណូលរបស់ខ្លួន អ្នកផ្តល់ចម្លើយនឹងប្រើប្រាស់នូវដំណោះស្រាយផ្សេងៗគ្នា ក្នុងនោះ ជិតពាក់កណ្តាល (៤៨.៧%) នឹងចូលរួមក្នុងការងារបន្ថែម ខណៈពេលដែល ៣៧.៤% នឹងប្តូររបបអាហាររបស់ពួកគេ គឺបរិភោគតិចជាងក្នុងមួយថ្ងៃ ឬបរិភោគអាហារតិចជាងមុន។ លើសពីនេះទៀត ៣១.៦% ពឹងទៅរកការខ្ចីបុលប្រាក់។

របបគាំពារសង្គមដែលមានការចាប់អារម្មណ៍ពីកសិករ៖



ការថែទាំសុខភាពត្រូវបានចាត់ទុកថាជារបបដែលសមស្របបំផុត ដោយសារមិនទាន់មានការគ្រប់ដណ្តប់ការថែទាំសុខភាពជាសកល និងការចំណាយលើថែទាំ និងការព្យាបាលមានតម្លៃថ្លៃ។

ចំណេះដឹង និងព័ត៌មានអំពីរបបសន្តិសុខសង្គម៖ កសិករខ្នាតតូចដែលបានស្ទង់មតិបង្ហាញពីការយល់ដឹងនៅមានកម្រិតទាក់ទងនឹងរបបសន្តិសុខសង្គមនីមួយៗដែលកំពុងអនុវត្តជាពិសេស ព័ត៌មានសំខាន់ៗ រួមមាន ការចុះឈ្មោះជាសមាជិករបបសន្តិសុខសង្គមដែលកំពុងអនុវត្ត ទំហំភាគទានដែលត្រូវបង់ និងដំណើរការនៃការទូរទាត់អត្ថប្រយោជន៍ ។ ជាង ៩៤% នៃអ្នកឆ្លើយតបបានសង្កត់ធ្ងន់លើតម្រូវការទទួលបានព័ត៌មាន ដែលក្នុងនោះ៨០.៧% ស្នើឡើងអោយមានការរៀបចំវេទិកាផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន និងកិច្ចប្រជុំដែលសម្របសម្រួលដោយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ។

ឧបសគ្គចំពោះការចូលរួមជាមួយបេឡាជាតិរបបសន្តិសុខសង្គម៖ ការសិក្សាបានបង្ហាញថា មានឧបសគ្គធំៗចំនួនបី ដែលរារាំងដល់ការចូលរួមរបស់កសិករខ្នាតតូចទាំងបុរស និងស្ត្រីជាមួយ ប.ស.ស. រួមមាន៖

- កង្វះលទ្ធភាពទទួលបានព័ត៌មានពេញលេញអំពីរបបសន្តិសុខសង្គម (**៧០.៨%**)
- កង្វះការយល់ដឹងអំពីដំណើរការរដ្ឋបាលទាក់ទងនឹងការចុះឈ្មោះជាសមាជិក (**៦០.២%**)
- កង្វះចំណេះដឹងអំពីអត្ថប្រយោជន៍នៃរបបនីមួយៗ (**៤៧.៤%**)

បញ្ហាប្រឈមចំពោះការបង់ភាគទានទៀងទាត់៖ ផ្អែកលើប្រាក់ចំណូល និងការចំណាយប្រចាំខែជាមធ្យម ការស្ទង់មតិបង្ហាញថា ជាងពាក់កណ្តាល (៥៦.៧ ភាគរយ) នៃកសិករខ្នាតតូចមិនមានប្រាក់សន្សំប្រចាំខែទេ មានន័យថា ក្រៅពីការចំណាយប្រចាំខែរួច ពួកគាត់ភាគច្រើនមិនមានលុយសល់ប្រចាំខែ ដើម្បីសន្សំ ឬបម្រុងទុកសម្រាប់សុវត្ថិភាពនៅពេលអនាគត ឬសម្រាប់បង់ភាគទានជាមួយប.ស.ស.ឡើយ។ កសិករខ្នាតតូចបានកំណត់ពីឧបសគ្គធំៗចំនួនបី ដែលធ្វើឱ្យពួកគេមិនអាចចូលរួមបង់ភាគទានទៀងទាត់ជាមួយរបបសន្តិសុខសង្គមបាន រួមមាន៖ ប្រាក់ចំណូលទាប(៤០.១%) ប្រាក់ចំណូលមិនទៀងទាត់ (៣១.៣%) និងចំណាយក្នុងគ្រួសារកើនឡើង(១៨.៨%) ។



លទ្ធភាពក្នុងការបង់ភាគទានដល់បេឡាជាតិរបបសន្តិសុខសង្គម៖ ផ្អែកលើចំណូល និងការចំណាយបច្ចុប្បន្ន កសិករខ្នាតតូចចំនួន **៨៤.៩%** បានលើឡើងថាពួកគាត់អាចបង់ភាគទានត្រឹម **២ដុល្លារក្នុងមួយខែ** សម្រាប់របបសន្តិសុខសង្គមដែលមានស្រាប់។ លើសពីនេះ ជាងបីភាគបួន (**៧៤.៤%**) នៃអ្នកផ្តល់ចម្លើយទាំងពីរភេទ ចាប់អារម្មណ៍លើការបង់ភាគទានប្រចាំខែ។

ផ្អែកលើការសិក្សាស្រាវជ្រាវបានបង្ហាញថា **៦៨.៥%**នៃអ្នកផ្តល់ចម្លើយ ចង់ឱ្យមានច្បាប់កំណត់ពីការលើកលែងការបង់ភាគទានរបស់កសិករខ្នាតតូច(ទទួលបានដោយមិនចាំបាច់បង់ភាគទាន)។ លើសពីនេះ **៦៤.១%** បានលើកឡើងពីតម្រូវការច្បាប់ និងគតិយុត្តិនានាដែលជួយសម្រួលដល់កសិករខ្នាតតូចអាចចូលរួមបង់ភាគទានដល់បេឡាជាតិរបបសន្តិសុខសង្គមបាន។ យោបល់បន្ថែមទៀតរួមមានការធ្វើវិសោធនកម្មច្បាប់ដើម្បីអនុញ្ញាតឱ្យសមាជិកគ្រួសារទទួលបានអត្ថប្រយោជន៍ផ្នែកថែទាំសុខភាព(**៣៦.៥%**) និងស្នើសុំការចូលរួមពីរដ្ឋាភិបាលក្នុងបង់ភាគទាន(**២០.៦%**)។

៤. ដំណោះស្រាយលើគោលនយោបាយ និងអនុសាសន៍

ផ្អែកលើលទ្ធផលសំខាន់ៗពីការស្រាវជ្រាវនេះ ស្របគ្នានឹងផែនការពង្រឹកធានារ៉ាប់រងសង្គមតាមការបង់ភាគទានស្ម័គ្រចិត្តដល់កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការស្រាវជ្រាវនេះបានលើកជាអនុសាសន៍សំខាន់ៗ និងចាំបាច់ដូចខាងក្រោម ដើម្បីពង្រឹកវិសាលភាពនៃការគ្របដណ្តប់ដល់កសិករខ្នាតតូចប្រកបដោយបរិយាបន្ន៖



សម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖

- **វិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គម ឆ្នាំ២០១៩ ដើម្បីបញ្ចូលកសិករខ្នាតតូចទៅក្នុងរបបប.ស.ស.៖** ដើម្បីគ្របដណ្តប់ទៅក្នុងរបបប.ស.ស. ដែលមានក្នុងពេលបច្ចុប្បន្ន និងសម្រួលការចូលរួមដល់កសិករខ្នាតតូច ប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវអនុម័ត និងធ្វើវិសោធនកម្មផ្នែកខ្លះៗនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ឆ្នាំ ២០១៩។ ថ្វីបើវិសាលភាពនៅក្នុងច្បាប់នេះបានគ្រប់ដណ្តប់លើបុគ្គលស្ម័យនិយោជន៍ហើយក្តី ប៉ុន្តែមិនបានបញ្ជាក់ជាក់លាក់ឱ្យចំកសិករខ្នាតតូចនៅឡើយ។ បន្ថែមលើការបញ្ចូលកសិករខ្នាតតូចទៅក្នុងដែនសមត្ថកិច្ចនៃច្បាប់ សកម្មភាពសេដ្ឋកិច្ច រួមមានកម្រិតនៃប្រាក់ចំណូលគួរត្រូវបានគិតគូរ។ បន្ថែមពីនេះ ការផ្តល់ជូនចាំបាច់ផ្សេងទៀតដូចជាការដាក់បញ្ចូលសមាជិកគ្រួសាររបស់កសិករខ្នាតតូច ដើម្បីទទួលបានអត្ថប្រយោជន៍ពីការថែទាំសុខភាពក៏គួរតែមានផងដែរ។
- **ត្រូវមានយន្តការសមស្រប សម្រាប់ការបង់ភាគទាន និងចំការួមចំណែកពីរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាប្រឈមលើលទ្ធភាពនៃការបង់ភាគទាន៖** ដោយសារតែកសិករខ្នាតតូចមានកម្រិតប្រាក់ចំណូលទាប និងមិនទៀងទាត់ សំណូមពរគឺការឧបត្ថម្ភធនពីរដ្ឋមួយផ្នែកនៅដំណាក់កាលដំបូង និងបន្តយជាបន្តបន្ទាប់ រហូតដល់ការបង់ភាគទានទាំងស្រុងដោយកសិករខ្នាតតូច។ ជាងនេះទៅទៀត ពីទស្សនៈជំនួយមនុស្សធម៌ ក្នុងកំឡុងពេលដែលមានវិបត្តិធ្ងន់ធ្ងរ និងវិបត្តិដែលបណ្តាលមកពីអាកាសធាតុ រាជរដ្ឋាភិបាលគួរតែឧបត្ថម្ភធនទាំងស្រុងទៅលើការបង់ភាគទានទៅកាន់ប.ស.ស. ដើម្បីជួយរក្សាលំនឹងជីវភាពរបស់កសិករខ្នាតតូច និងដោះស្រាយស្ថានភាពរងគ្រោះក្នុងកំឡុងពេលនោះ។
- **សម្របយន្តការបង់ភាគទានដែលមានលក្ខណៈបត់បែន៖** ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានាដែលកសិករខ្នាតតូចជួបប្រទះក្នុងការងារកសិកម្ម និងលើកទឹកចិត្តដល់ការចូលរួមជាសមាជិកប.ស.ស. រាជរដ្ឋាភិបាលគួរកំណត់ និងអនុវត្តនូវទំហំ ឬកម្រិតភាគទាន និងពេលវេលាបង់ភាគទានទៅប.ស.ស. ដែលមានលក្ខណៈបត់បែនសមស្រប។
- **ភាពគ្រប់គ្រាន់នៃអត្ថប្រយោជន៍ដែលទទួលបាន៖** ដើម្បីទាក់ទាញ និងការគាំទ្រយូរអង្វែង រាជរដ្ឋាភិបាលត្រូវពិចារណាដល់ការបញ្ចូលនូវអត្ថប្រយោជន៍ពេញវ័ដ្ឋជីវិត និងអត្ថប្រយោជន៍លើកទឹកចិត្តផ្សេងៗបន្ថែមទៀត ផ្តើមចេញពីការថែទាំសុខភាព និង អត្ថប្រយោជន៍មាតុភាព សោធន និងគ្រោះថ្នាក់ការងារ និងបន្តអនុវត្តរបប សេវា ឬអត្ថប្រយោជន៍ថ្មីៗផ្សេងៗទៀតជាបន្តបន្ទាប់។ បន្ថែមពីនេះ មធ្យោបាយធ្វើដំណើរសាធារណៈ គួរតែមានដល់គ្រួសារកសិករដែលរស់នៅតំបន់ដាច់ស្រយ៉ាល ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការទៅទទួលសេវាថែទាំសុខភាពទាន់ពេលវេលា។ ប្រសិនបើមិនមានមធ្យោបាយធ្វើដំណើរសាធារណៈ រាជរដ្ឋាភិបាលគួរតែផ្តល់ជូន ឬទូរទាត់នូវថ្លៃធ្វើដំណើរដែលពួកគាត់បានចំណាយ នៅពេលដែលទៅមន្ទីរពេទ្យ ឬកន្លែងថែទាំសុខភាពនានា។
- **ដាក់បញ្ចូលការឆ្លើយតបតម្រូវការយេនឌ័រជាក់លាក់ទៅក្នុងយន្តការពង្រឹកវិសាលភាពរបស់ប.ស.ស.៖** ផ្អែកលើហានិភ័យជាច្រើនទៀតដែលស្ត្រីជាកសិករខ្នាតតូចជួបប្រទះនៅក្នុងវ័យបន្តពូជ រួមមាន មាតុភាព (មុន កំឡុង

ពេល និងក្រោយសម្រាលកូន) ការថែទាំកុមារ និងសុខភាពបន្តពូជជាដើម គោលនយោបាយ និងច្បាប់ ប.ស.ស. និងការពង្រីកច្បាប់នានាដើម្បីកសិករ ត្រូវតែយកចិត្តទុកដាក់គិតគូរ និងឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។ រាជរដ្ឋាភិបាលគួរពិចារណាអំពីវិធីសាស្ត្រ និងជម្រើសផ្សេងៗដូចជា ការឧបត្ថម្ភធនទៅលើការបង់ភាគទាន ការផ្តល់ជូននូវអត្ថប្រយោជន៍គាំពារមាតុភាព ទម្រង់បង់ភាគទានផ្សេងៗដែលមានលក្ខណៈបត់បែន និងកំណត់តម្រូវការរដ្ឋបាលដែលមានលក្ខណៈសមស្រប ឆ្លើយតបនឹងយេនឌ័រ។

- **ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលចល័ត ដើម្បីជួយសម្រួលដល់ការទទួលបានការគាំពារសង្គម៖** ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលចល័តមានសារៈសំខាន់ណាស់ ក្នុងការជួយដល់ការផ្តល់សេវាប.ស.ស.កាន់តែប្រសើរឡើងសម្រាប់កសិករខ្នាតតូច។ រាជរដ្ឋាភិបាលគួរពិចារណាបង្កើតនូវមធ្យោបាយបច្ចេកវិទ្យាឌីជីថលចល័តដើម្បីសម្រួលដល់ការចុះឈ្មោះសមាជិក ការបង់ភាគទាន ការទូទាត់អត្ថប្រយោជន៍ និងឧបករណ៍ផ្សេងទៀត ដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលដល់ការផ្តល់សេវាកម្ម។ បន្ថែមពីនេះ គួរធ្វើការជាមួយសង្គមស៊ីវិល និងលើកទឹកចិត្តដល់ពួកគេដើម្បីប្រើប្រាស់ និងផ្សព្វផ្សាយមធ្យោបាយបច្ចេកវិទ្យាឌីជីថលចល័តទាំងអស់នោះទៅកាន់កសិករខ្នាតតូច។
- **ធ្វើឱ្យការចុះឈ្មោះងាយស្រួល និងងាយធ្វើបាន៖** ផ្អែកលើវត្តមានកសិករខ្នាតតូចនៅពាសពេញប្រទេសកម្ពុជា ដំណើរការចុះឈ្មោះពួកគេទៅក្នុងប.ស.ស.អាចធ្វើឡើងនៅកម្រិតឃុំ សង្កាត់។ ការធ្វើដូច្នេះ នឹងធ្វើឱ្យការចុះឈ្មោះមានភាពងាយស្រួល មិនសូវមានបញ្ហា និងការរំខាន។ ជាងនេះទៅទៀត ការងារផ្សេងៗទៀតក៏គួរធ្វើនៅកម្រិតឃុំសង្កាត់ដែរ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កសិករខ្នាតតូចអាចទទួលបានពត៌មានថ្មីៗទាន់ពេលវេលា រួមទាំងការដាក់មតិជំទាស់ សំណើរ និងសំណូមពរនានាជាដើម។
- **ធ្វើការសិក្សាទ្រង់ទ្រាយធំកម្រិតថ្នាក់ជាតិ៖** ប.ស.ស. អាចពិចារណាធ្វើការសិក្សាស្ទង់មតិជាលក្ខណៈទ្រង់ទ្រាយធំកម្រិតជាតិ ទៅលើលទ្ធភាពបង់ភាគទានរបស់កសិករខ្នាតតូច ដោយពិនិត្យមើលលើកម្រិតហានិភ័យ និងភាពងាយរងគ្រោះដែលកសិករខ្នាតតូចជួបប្រទៈនៅតាមតំបន់ផ្សេងៗ។
- **តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ លើការអនុវត្តរបស់អ្នកផ្តល់សេវា៖** ដើម្បីធានាការផ្តល់សេវាប្រកបដោយគុណភាព តម្រូវឱ្យមានការតាមដានជាប្រចាំ និងការវាយតម្លៃជាដំណាក់កាលៗទៅលើការអនុវត្តរបស់ដៃគូរប.ស.ស. ទាំងអស់ ក៏ដូចជាអ្នកផ្តល់សេវា ដូចជាមន្ទីរពេទ្យ មណ្ឌលសុខភាព ជាដើម។ ការងារនេះនឹងជួយផ្តល់ទំនុកចិត្តដល់កសិករខ្នាតតូចទៅលើការផ្តល់សេវាកម្ម។

សម្រាប់រាជរដ្ឋាភិបាល សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល

- **ផ្សព្វផ្សាយពត៌មានដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែស៊ីជម្រៅទៅដល់កសិករខ្នាតតូច អំពីច្បាប់ ការណែនាំ និងសារាចរនានាពាក់ព័ន្ធនឹងប.ស.ស.៖** ពត៌មានស្តីពីច្បាប់ សារាចរ គោលការណ៍ របប ប.ស.ស. អត្ថប្រយោជន៍ លក្ខខណ្ឌស្របច្បាប់ ភាគទានសមាជិកភាព និតិវិធីរដ្ឋបាលផ្សេងៗ ក៏ដូចជាសិទ្ធិ និងកាតព្វកិច្ចនានារបស់សមាជិក គួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅកាន់កសិករខ្នាតតូច រួមទាំងកសិករដែលមិនអាចមានលទ្ធភាពចូលរួមក្នុងរបបប.ស.ស.ផងដែរ។ សកម្មភាពទាំងនេះអាចធ្វើឡើងតាមរយៈកិច្ចប្រជុំនៅកម្រិតមូលដ្ឋានជាមួយអាជ្ញាធរភូមិ។ បន្ថែមពីលើនេះ មធ្យោបាយផ្សេងទៀតក្នុងការផ្សព្វផ្សាយ ពត៌មានទៅកាន់កសិករខ្នាតតូចប្រកបដោយប្រសិទ្ធិភាព គឺតាមរយៈអង្គការមូលដ្ឋាននៅកម្រិតភូមិ ដូចជា សហករណ៍ ឬសហគមន៍កសិកម្ម និងក្រុមជួយខ្លួនឯង។
- **ប្រើប្រាស់សេវាកម្មរបស់សហករណ៍ ឬសហគមន៍កសិកម្ម និងក្រុមជួយខ្លួនឯង៖** ហានិភ័យ និងភាពងាយរងគ្រោះផ្នែករូបវន្ត និងសង្គម ដែលកសិករខ្នាតតូចប្រឈមអាចដោះស្រាយបានរួមគ្នាតាមរយៈការប្រើប្រាស់សហករណ៍ ឬសហគមន៍កសិកម្ម និងក្រុមជួយខ្លួនឯងនៅមូលដ្ឋាន។ ជាងនេះទៅទៀត អង្គការមូលដ្ឋាននៅកម្រិតភូមិអាចជួយដល់ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងទៅកាន់កសិកររំពីភាពចាំបាច់ សារៈសំខាន់នៃការចូលរួមជាសមាជិក និងអត្ថប្រយោជន៍គាំពារសង្គម រួមទាំងគាំពារសង្គមដែលឆ្លើយតបនឹងគ្រោះអាសន្នផងដែរ។ ក្នុងនាមជាភ្នាក់ងារនៅចន្លោះរវាងកសិករ និងរាជរដ្ឋាភិបាល ពួកគេអាចជួយសម្របសម្រួលដល់ការចុះឈ្មោះកសិករជាក្រុមទៅកាន់ប.ស.ស.បាន។



Photo by: Oxfam

ចូលរួមអនុវត្តដោយ៖

CAMBODIAN CHILDREN'S FUND

Y R D P

CENTRAL

CDPO

HelpAge Cambodia
age helps

OXFAM

IDEA

CLC

CCAWDU

CFSWF

ផ្តល់មូលនិធិដោយ៖

Funded by
the European Union